# ប្រ ក ា ស
## ស្តីពី
## ការទូទាត់ភាគលាភជាមុន

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/ ២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/ ១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/ ០៣៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន

## ស ំ រេ ច

**ប្រការ ១ .-**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យទូទាត់ភាគលាភបាន លុះត្រាតែប្រាក់ចំណេញត្រូវបានទទួលស្គាល់ជាក់លាក់ ។

**ប្រការ ២ .-**

ប្រាក់ចំណេញប្រចាំឆ្នាំត្រូវបានទទួលស្គាល់ជាក់លាក់នៅពេលដែលស្នងការគណនីឯករាជ្យបានអនុម័តបញ្ជីគណនេយ្យប្រចាំឆ្នាំ ។

ធនាគារមិនអាចទូទាត់ភាគលាភនៅមុនពេលអនុមតិនេះទេ ។

**ប្រការ ៣ ._**

ប្រសិនបើភាគលាភត្រូវបានទូទាត់ជាមុន ធនាគារជាតិនៃកម្ពុជាអាចបង្ខំឱ្យភាគទុនិកសងភាគលាភដែលបានទូទាត់ជាមុនមកវិញយ៉ាងឆាប់ដោយបូកបន្ថែមជាមួយការប្រាក់ដែលបានគណនាដូច ឥណទានលើសសមតុល្យចំពោះឯកត្តជន ។

**ប្រការ ៤ ._**

ថ្វីបើមានប្រការ ៣ ក៏ដោយ ការខកខានមិនបានគោរពតាមខ្លឹមសារនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មស្របតាមមាត្រា ៥២នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៥ ._**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ៦ ._**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ មករា ឆ្នាំ ២០០៤

**ទេសាភិបាល**

**<u>កន្លែងទទួល</u>**

- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**<u>ចម្លងជូន</u>**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះក្នុងរាជកិច្ច"